ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ**

**វាយតំលៃនិងប្រគល់កិច្ចសន្យា គបវប (PEAC)**

លេខ:....259.........PEAC អក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពិគ្រោះថ្លៃលើ ថ្លៃសំភារៈឧបករណ៍និងឈ្នួលពលកម្ម រៀបចំប្រព័ន្ធបណ្តាញកុំព្យូទ័រ និង ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព ជូនអគ្គិសនីព្រៃវែង

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់ បណ្តាក្រុមហ៊ុនផ្គត់ផ្គង់សំភារៈ-កុំព្យូទ័រ ក្នុងស្រុក ( គិតទាំងសហគ្រាសឯកកត្តបុគ្គល ) និង ក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបាន ជ្រាបថា : អគ្គិសនីកម្ពុជារៀបចំការងារពិគ្រោះថ្លៃ លើ ថ្លៃសំភារៈឧបករណ៍ និង ឈ្នួលពលកម្ម រៀបចំប្រព័ន្ធបណ្តាញកុំព្យូទ័រ និង ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព ជូនអគ្គិសនីព្រៃវែង ។ អគ្គិសនីកម្ពុជា បានរៀបចំឯកសារពិគ្រោះថ្លៃសំរាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមពិគ្រោះថ្លៃនិងមានចែកជូននៅអង្គភាពលទ្ធកម្ម អាស័យដ្ឋាន ផ្លូវព្រះយុគន្ធរ , សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ២៧-០៣-២០១៤ តទៅរៀងរាល់ម៉ោងធ្វើការ ។ ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត រួចប្រគល់ជូនអង្គភាពលទ្ធកម្មនៃអគ្គិសនីកម្ពុជា យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ១០-០៤- ២០១៤ វេលាម៉ោង១១:០០នាទី,កាលបរិច្ឆេទបើកឯកសារពិគ្រោះថ្លៃនៅថ្ងៃទី ១០-០៤-២០១៤ វេលាម៉ោង១៥:៣០នាទី ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់ឯកសារពិគ្រោះថ្លៃបានតែមួយគត់ ។ ក្រុមហ៊ុនដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មនៃអគ្គិសនីកម្ពុជា ដើម្បីទទួលយកឯកសារពិគ្រោះថ្លៃ និង សាកសួរពត៌មានផ្សេងៗ ដែលមានទាក់ទងនឹងការងារពិគ្រោះថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី 27 ខែ 03 ឆ្នាំ២០១៤

**ប្រធានគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ**

**វាយតំលៃនិងប្រគល់កិច្ចសន្យា គបវប(PEAC)**

**ឆឹង_អ៊ឹង**

សូមទាក់ទង

ទូរស័ព្ទលេខ :០២៣ ៦៧៦ ៦០០៧

website : www.edc.com.kh

ចំលងជូន :

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-នាយកដ្ឋានលទ្ធកម្មសាធារណៈ

-ឯកសារ